ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
...១១៥១...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាគណៈឱសថការីជាតិ សម្រាប់អាណត្តិទី១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈឱសថការីកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាគណៈឱសថការីជាតិអាណត្តិទី១ ចំនួន២២ រូប ៖

| | | |
|---|---|---|
| ១-លោកឱសថបណ្ឌិត | **ហោច ម៉ិនគៀត** | តំណាងថ្នាក់កណ្តាល |
| ២- លោកស្រីសាស្ត្រាចារ្យមហាបរិញ្ញា | **ទេព ឡើ** | តំណាងមហាវិទ្យាល័យឱសថសាស្ត្រ |
| ៣- លោកឱសថការី | **ជា ឈីវស្រុច** | តំណាងថ្នាក់កណ្តាល |
| ៤- លោកសាស្ត្រាចារ្យរង | **គេត វណ្ណសិទ្ធី** | តំណាងថ្នាក់កណ្តាល |
| ៥- លោកស្រីសាស្ត្រាចារ្យមហាបរិញ្ញា | **គាត គួច** | តំណាងថ្នាក់កណ្តាល |
| ៦- លោកស្រីឱសថការី | **យួន ច័ន្ទវណ្ណា** | តំណាងថ្នាក់កណ្តាល |
| ៧- លោកឱសថការី | **សួន រិទ្ធ** | តំណាងរាជធានីភ្នំពេញ |
| ៨-លោកឱសថការី | **ម៉ៅ ជារេត** | តំណាងរាជធានីភ្នំពេញ |
| ៩-លោកឱសថការី | **ហាស់ អសនី** | តំណាងខេត្តបាត់ដំបង ពោធិសាត់ ប៉ៃលិន |
| ១០-លោកស្រីឱសថការី | **ម៉ាច ជានី** | តំណាងខេត្តកំពង់ចាម |
| ១១-លោកឱសថការី | **ពិគុណា ប៉ុណ្ណារ៉ា** | តំណាងខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ |
| ១២-លោកឱសថការី | **លុយ សុវណ្ណា** | តំណាងខេត្តកំពង់ឆ្នាំង |
| ១៣-លោកឱសថការី | **ជិន ប៉ូលីនណា** | តំណាងខេត្តកំពង់ធំ |
| ១៤-លោកឱសថការី | **កែច ស៊ីនណាវ** | តំណាងខេត្តកំពង់ស្ពឺ |
| ១៥-លោកឱសថការី | **លឹម ចាន់** | តំណាងខេត្តកំពត កែប |
| ១៦-លោកឱសថការី | **កូ តាត** | តំណាងខេត្តកណ្តាល |
| ១៧-លោកឱសថការី | **ម៉ូច សុជាត** | តំណាងខេត្តក្រចេះ |
| ១៨-លោកឱសថការី | **លី ច័ន្ទណារិទ្ធ** | តំណាងខេត្តរតនគីរី ស្ទឹងត្រែង មណ្ឌលគីរី ព្រះវិហារ |
| ១៩-លោកឱសថការី | **ផុល ពន្លឺ** | តំណាងខេត្តព្រៃវែង ស្វាយរៀង |
| ២០-លោកស្រីឱសថការី | **លី វណ្ណៈ** | តំណាងខេត្តសៀមរាប |
| ២១-លោកឱសថការី | **សេច ណុច** | តំណាងខេត្តព្រះសីហនុ កោះកុង |
| ២២-លោកឱសថការី | **ផាន់ ម៉ាន់** | តំណាងខេត្តតាកែវ ។ |

**មាត្រា ២.-**

ត្រូវបានទទួលស្គាល់សមាសភាពការិយាល័យក្រុមប្រឹក្សាគណៈឱសថការីជាតិ ចំនួន ៧ រូប ដូចខាងក្រោម៖

១-លោកឱសថបណ្ឌិត **ហោច ម៉ិនគៀត** ជា ប្រធាន

២- លោកស្រីសាស្ត្រាចារ្យមហាបរិញ្ញា **ធេពរឡើ** ជា អនុប្រធានទី១

៣- លោកឱសថការី **ជា ឈីវស្រុន** ជា អនុប្រធានទី២

៤- លោកសាស្ត្រាចារ្យរង **កេតុ វណ្ណាសិទ្ធី** ជា អគ្គលេខាធិការ

៥- លោកឱសថការី **ស្មួន រិទ្ធ** ជា អគ្គលេខាធិការរង

៦- លោកស្រីសាស្ត្រាចារ្យមហាបរិញ្ញា **គាត ភួន** ជា អគ្គហេរញ្ញិក

៧- លោកស្រីឱសថការី **យូន វឌ្ឍាវណ្ណា** ជា អគ្គហេរញ្ញិករង ។

**មាត្រា ៣.-**

ត្រូវបានទទួលស្គាល់អ្នកពិគ្រោះយោបល់ក្រុមប្រឹក្សាគណៈឱសថការីជាតិ ចំនួន ០២ រូប ៖

១-ឯកឧត្តមឱសថការី **អ៊ី វណ្ណក** តំណាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល

២-លោកស្រីឱសថការី **គង់ សត្យា** តំណាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៤.-**

ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា និងការិយាល័យគណៈឱសថការីជាតិ ព្រមទាំងសមាជិកពិគ្រោះយោបល់មានសុពលភាពរយៈពេល៦ឆ្នាំ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ខេត្ត ដែលពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាគណៈឱសថការីជាតិ និងសមាសភាពដូចមានចែងក្នុងមាត្រា១ ដល់ មាត្រា៣ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>ន្លែងទទួល</u> :

សួងព្រះបរមរាជវាំង

; ខាធិការដ្ឋានព្រឹទ្ធសភា

;លេខាធិការដ្ឋានរដ្ឋសភា

;លេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

;លេខាធិការរាជរដ្ឋាភិបាល

កាល័យសម្តេចនាយករដ្ឋមន្ត្រី

កាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

មាត្រា ៥

កិច្ច

សារ-កាលប្បវត្តិ